Khmer / ខ្មែរ

# ការចូលរួមក្នុងការបោះឆ្នោតសាលាសង្កាត់ប្រចាំតំបន់របស់អ្នក គឺជាវិធីដ៏ផ្ទាល់មួយ ដែលអ្នកអាចធ្វើឱ្យមានភាពខុសប្លែកដល់ជីវិតប្រចាំថ្ងៃ នៅក្នុងសហគមន៍របស់អ្នក។

ចូរពិចារណាមួយភ្លែត អំពីរបៀបដែលជីវិតរស់នៅប្រចាំថ្ងៃត្រូវបានកែលម្អ ដោយសារសេវាកម្មជាច្រើនដែលសាលាក្រុងផ្តល់ជូន។ ស្រមៃមើលសហគមន៍របស់អ្នកដោយគ្មានភ្លើងបំភ្លឺផ្លូវថ្នល់ ការប្រមូលសំរាម ផ្លូវដើរ បណ្ណាល័យ សួនកុមារ និងកន្លែងលេងកីឡា សាលសហគមន៍ សេវាកម្មមនុស្សវ័យចំណាស់ ហើយបញ្ជីនេះនៅមានបន្តទៅទៀត។

ការសម្រេចអំពីសេវាកម្ម គោលនយោបាយ និងគម្រោងរបស់សាលាសង្កាត់ ត្រូវបានបង្កើតឡើងដោយមនុស្សដូចអ្នក ដែលតំណាងឱ្យទស្សនៈរបស់ពលរដ្ឋក្នុងតំបន់មូលដ្ឋាន។

## សាលាសង្កាត់ រដ្ឋអូស្ត្រាលីខាងត្បូង ជាផ្នែក ប្រចាំថ្ងៃ របស់អ្នក

- ធ្វើឱ្យមានភាពខុសប្លែក -

## ចុះឈ្មោះ

ឱ្យបានទាន់ថ្ងៃសុក្រ ទី 10 ខែសីហា ឆ្នាំ 2018

## ជ្រើសតាំង

ឱ្យបានទាន់ថ្ងៃអង្គារ៍ ទី 18 ខែកញ្ញា ឆ្នាំ 2018

## បោះឆ្នោត

ឱ្យបានមុនថ្ងៃសុក្រ ទី 9 ខែវិច្ឆិកា ឆ្នាំ 2018

-2018-
ការបោះឆ្នោតសាលាសង្កាត់

Local Government Association of South Australia

អនុញ្ញាតដោយលោក Matt Pinnegar
148 Frome Street, Adelaide SA 5000
អ៊ីម៉ែល៖ lgasa@lga.sa.gov.au
ទូរស័ព្ទ៖ (08) 8224 2000










## តើអ្នកអាចធ្វើឱ្យមានភាពខុសប្លែកយ៉ាងដូចម្តេច?

អ្នកអាចដាក់ឥទ្ធិពលលើអ្វីដែលកើតមានឡើងនៅក្នុងសហគមន៍មូលដ្ឋានរបស់អ្នកតាមវិធីពីរយ៉ាង - ដោយការតែងតាំងមុខតំណែងមួយនៅសាលាសង្កាត់ ឬដោយការបោះឆ្នោតសម្រាប់បេក្ខជនដែលជាតំណាងទស្សនៈរបស់អ្នក។

## ការចុះឈ្មោះបោះឆ្នោត

ការបោះឆ្នោតនៅក្នុងការបោះឆ្នោតសាលាសង្កាត់ គឺបើកចំហដល់មនុស្សច្រើនជាងការបោះឆ្នោតរដ្ឋ និងសហព័ន្ធ។ ទោះបីជាអ្នកមិនមែនជាពលរដ្ឋអូស្ត្រាលី ហើយពុំមានឈ្មោះចុះក្នុងបញ្ជីបោះឆ្នោតរដ្ឋ(សភាតំណាងរាស្ត្រ)ក៏ដោយ អ្នកអាចបោះឆ្នោតបាននៅក្នុងការបោះឆ្នោតសាលាសង្កាត់មួយ គឺឱ្យតែអ្នកមានអាយុលើសពី 18 ឆ្នាំ ហើយបានរស់នៅក្នុងតំបន់សាលាសង្កាត់ច្រើនជាងមួយខែ។ អ្នកក៏អាចបោះឆ្នោតនៅក្នុងការបោះឆ្នោតសាលាសង្កាត់បានដែរ ប្រសិនបើអ្នកមានអចលទ្រព្យដែលត្រូវបង់ពន្ធដីធ្លីនៅក្នុងតំបន់ ដោយមិនគិតថាតើអ្នករស់នៅក្នុងអចលទ្រព្យនោះឬអត់។

ភាពខុសគ្នាដ៏សំខាន់មួយទៀតគឺថា អាជីវកម្ម និងស្ថាប័នសាជីវកម្មអាចបោះឆ្នោតបាន នៅក្នុងការបោះឆ្នោតសាលាសង្កាត់។

សម្រាប់ព័ត៌មានបន្ថែមអំពីសិទ្ធិ ហើយដើម្បីទទួលបានទម្រង់បែបបទចុះឈ្មោះអ្នកបោះឆ្នោតសម្រាប់បញ្ជីបោះឆ្នោតបន្ថែម សូមចូលទៅកាន់វ៉ិបសៃ www.lga.sa.gov.au/councilelections

**ការចុះឈ្មោះបិទនៅម៉ោង៥ល្ងាច ថ្ងៃសុក្រទី 10 ខែសីហា ឆ្នាំ 2018។**

## ការជ្រើសតាំងមុខតំណែងនៅសាលាសង្កាត់

ប្រសិនបើអ្នកមានសិទ្ធិបោះឆ្នោត នៅក្នុងការបោះឆ្នោតសាលាសង្កាត់ប្រចាំតំបន់របស់អ្នក អ្នកក៏ប្រហែលជាមានសិទ្ធិឈរឈ្មោះសម្រាប់មុខដំណែងនៅតាមសាលាសង្កាត់ផងដែរ។ ដោយមានករណីលើកលែងតិចតួច (ដូចជាការក្ស័យធនដែលនៅជំពាក់បំណុល ឬត្រូវបានដកហូតសិទ្ធិដោយបញ្ហារបស់តុលាការ) អ្នកអាចតែងតាំងសម្រាប់មុខតំណែងមួយនៅសាលាសង្កាត់ ដោយមិនគិតពីគុណសម្បត្តិ សាសនា ពូជសាសន៍ ភេទ បទពិសោធន៍ ឬវិជ្ជាជីវៈ។ តាមការពិត សាលាសង្កាត់បានលើកទឹកចិត្តយ៉ាងសកម្មដើម្បីឱ្យមានការតែងតាំងពីប្រជាជនមកពីប្រវត្តិផ្សេងៗ ដើម្បីធានាថាមានតំណាងទស្សនៈទូលំទូលាយ។

ការក្លាយជាសមាជិកទីប្រឹក្សាសាលាសង្កាត់ អនុញ្ញាតឱ្យលោកអ្នកដាក់ឥទ្ធិពលលើការសម្រេចសំខាន់ៗ ដោះស្រាយបញ្ហាដែលជាកង្វល់ចំពោះអ្នក និងប៉ះពាល់ផ្ទាល់ដល់គុណភាពនៃជីវិតនៅក្នុងសហគមន៍របស់អ្នក។ ការធ្វើជាសមាជិកទីប្រឹក្សាសាលាសង្កាត់ម្នាក់ អាចទទួលផលល្អ និងជាទីពេញចិត្តតាមបំណង។ អ្នកនឹងរៀនដឹងច្រើន ហើយបង្កើតការតភ្ជាប់ផ្ទាល់ខ្លួនដ៏មានតម្លៃ។

សមាគមរដ្ឋាភិបាលប្រចាំតំបន់មូលដ្ឋាន និងសាលាសង្កាត់ជាច្រើនបានរៀបចំវគ្គផ្តល់ព័ត៌មានសម្រាប់បេក្ខជនដែលមានសក្តានុពល។ ដើម្បីស្វែងយល់បន្ថែមអំពីវគ្គសិក្ខាសាលាទាំងនេះ ឬរបៀបតែងតាំង សូមចូលទៅកាន់វ៉ិបសៃ www.lga.sa.gov.au/councilelections ។

**ការតែងតាំងសម្រាប់ការបោះឆ្នោតសាលាសង្កាត់ បើកនៅថ្ងៃអង្គារ៍ ទី 4 ខែកញ្ញា ហើយបិទនៅម៉ោង១២ថ្ងៃត្រង់ ថ្ងៃអង្គារ៍ ទី 18 ខែកញ្ញា ឆ្នាំ 2018 ។**

## ការបោះឆ្នោតនៅក្នុងការបោះឆ្នោតសាលាសង្កាត់ ឆ្នាំ 2018

ការបោះឆ្នោតនៅក្នុងការបោះឆ្នោតសាលាសង្កាត់ ត្រូវបានធ្វើឡើងតាមប្រៃសណីយ៍។ ប្រសិនបើអ្នកមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតរដ្ឋ (សភាតំណាងរាស្ត្រ) ឬបានបំពេញការចុះឈ្មោះចូលរួមក្នុងបញ្ជីបំពេញបន្ថែម អ្នកនឹងទទួលបានកញ្ចប់បោះឆ្នោតមួយ តាមប្រៃសណីយ៍នៅចុងខែតុលា ឆ្នាំ 2018 ។

ក្រដាសសន្លឹកឆ្នោតនៅក្នុងកញ្ចប់បោះឆ្នោតរបស់អ្នក នឹងបង្ហាញពីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតនៅក្នុងមណ្ឌលសាលាសង្កាត់របស់អ្នក។ ដើម្បីស្វែងយល់បន្ថែមអំពីបេក្ខជនម្នាក់ៗ និងអ្វីដែលពួកគេតំណាង សូមចូលទៅកាន់វ៉ិបសៃ www.lga.sa.gov.au/councilelections រួចបំពេញសន្លឹកសន្លឹកឆ្នោតរបស់អ្នក ហើយបញ្ជូនវាត្រឡប់មកវិញទៅក្នុងស្រោមសំបុត្រឆ្លើយតបដែលមានចារអាសយដ្ឋាន និងបង់ថ្លៃតែមរួចស្រេច។

**សន្លឹកឆ្នោតត្រូវតែបានទទួលមុនពេលម៉ោង 5 ល្ងាច ថ្ងៃសុក្រ ទី 9 ខែវិច្ឆិកា ឆ្នាំ 2018 ។**

## ចូលរួមទាក់ទិន និងធ្វើឱ្យមានភាពខុសប្លែក

លទ្ធិប្រជាធិបតេយ្យក្នុងតំបន់មូលដ្ឋាន គឺជាលក្ខណៈសំខាន់មួយនៃជីវិតរស់នៅក្នុងប្រទេសអូស្ត្រាលី ហើយសាលាសង្កាត់មានឥទ្ធិពលយ៉ាងច្រើនក្រៃលែងចំពោះសហគមន៍ ជាងមនុស្សយល់ឃើញទៅទៀត។ សូមធ្វើឱ្យមានភាពខុសប្លែក ដោយចូលរួមក្នុងការបោះឆ្នោតសាលាសង្កាត់របស់អ្នក។

## សម្រាប់ព័ត៌មានបន្ថែម

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់វ៉ិបសៃរបស់សាលាសង្កាត់អ្នក ឬចូលមើលនៅត្រង់ www.lga.sa.gov.au/councilelections។